# អ្នកបានទទួលកាតចាក់វ៉ាក់សាំង COVID របស់អ្នក៖ តើអ្នកគួរធ្វើដូចម្តេចនៅពេលនេះ?




ពេលដែលអ្នកទទួលការចាក់វ៉ាក់សាំង COVID-19 អ្នកទទួលបានកាតចាក់វ៉ាក់សាំងដើម្បីធ្វើជាភ័ស្តុតាង។ រក្សាទុកវាឲ្យល្អ! អ្នកគួរតែរក្សាទុកវាឲ្យដូចជាកាតក្រេឌីត ប័ណ្ណបើកបរ ឬលិខិតឆ្លងដែនរបស់អ្នកអញ្ចឹងដែរ។ កាតរបស់អ្នកមិនត្រឹមតែជាការរំឭកពីកាលបរិច្ឆេទចាក់ប៉ុណ្ណោះទេ៖ វាជាកំណត់ត្រាផ្លូវការមួយដែលអ្នកអាចត្រូវការពេលធ្វើដំណើរ ចូលរួមព្រឹត្តិការណ៍ណាមួយ និងក៏អាចប្រើសម្រាប់ដូសរំលឹកលើកក្រោយៗទៀតផងដែរ។

អាជីវកម្មជាច្រើននៅក្នុងរដ្ឋវ៉ាស៊ីនតោន កំពុងផ្តល់រង្វាន់លើកទឹកចិត្តសម្រាប់អ្នកដែលមាន ភ័ស្តុតាងបញ្ជាក់ពីការទទួលបានការចាក់វ៉ាក់សាំងគ្រប់ចំនួនដូចជាការចុះតម្លៃ របស់ថែម ឬកៅអីដែលពួកគេពេញចិត្តសម្រាប់ព្រឹត្តិការណ៍ណាមួយ។ រក្សាកាតចាក់វ៉ាក់សាំងរបស់អ្នកទើបអ្នកអាចទទួលបានអត្ថប្រយោជន៍នៃការផ្តល់ជូនទាំងនេះ។

## *នេះជាគន្លឹះមានប្រយោជន៍ខ្លះៗដែលត្រូវចងចាំនៅពេលនិយាយពីការរក្សាកាតចាក់វ៉ាក់សាំងរបស់អ្នក៖*



- សូមរក្សាកាតចាក់វ៉ាក់សាំងរបស់អ្នកនៅចន្លោះពេលទទួលដូសរបស់អ្នកនិងក្រោយពេលចាក់រួចរាល់។
- សូម ថតរូបទាំងផ្នែកខាងមុខ និងខាងក្រោយនៃកាតរបស់អ្នកដើម្បីរក្សាវាក្នុងទម្រង់ឌីជីថល។ ពិចារណាផ្ញើវាតាមអ៊ីមែលរបស់អ្នក បង្កើតអាល់ប៊ុម ឬថេករូបនោះដើម្បីឲ្យអ្នកងាយស្រួលស្វែងរកវាម្តងទៀត។
- សូម ធ្វើការថតចម្លងប្រសិនបើអ្នកចង់ដាក់វាតាមខ្លួន។

---




- កុំ បោះវាចោល ឬធ្វើឲ្យបាត់!
- កុំបង្ហោះរូបលើប្រព័ន្ធអនឡាញបង្ហាញពីកាតចាក់វ៉ាក់សាំងរបស់អ្នក។ជំនួសមកវិញអ្នកអាចថតរូបអ្នកដោយការប្រើប្រាស់ ស្ទីកឃើរឌីជីថល (ជាភាសាអង់គ្លេសតែប៉ុណ្ណោះ) ដោយស្វែងរក #vaccinateWA ឬ#wadoh! សូមកុំភ្លេចថេក @WADeptHealth។
- កុំ អ៊ុតកាតច្បាប់ដើមរបស់អ្នក។ អ្នកអាចជ្រើសរើសធ្វើការអ៊ុតកាតចម្លងរបស់អ្នកដើម្បីដាក់តាមខ្លួន។




## តើមានអ្វីកើតឡើងប្រសិនបើអ្នកមិនមានកាតចាក់វ៉ាក់សាំង Center for Disease Control (CDC, មជ្ឈមណ្ឌលប្រយុទ្ធប្រឆាំងជំងឺ) របស់អ្នក?

ប្រសិនបើអ្នកភ្លេចកន្លែងដាក់ ឬបាត់កាតរបស់អ្នក សូមកុំបារម្ភ! អ្នកអាចទទួលបានភ័ស្តុតាងផ្លូវការនិងត្រូវបានផ្ទៀងផ្ទាត់នៃការចាក់វ៉ាក់សាំងរបស់អ្នកតាមអនឡាញដោយឥតគិតថ្លៃ។ គេហទំព័រMyIR គឺជាវិធីផ្លូវការរបស់រដ្ឋក្នុងការទទួលបានភ័ស្តុតាងនៃការចាក់វ៉ាក់សាំងក្នុងរដ្ឋវ៉ាស៊ីនតោន។ ដើម្បីទទួលបានឯកសាររបស់អ្នក សូមចូលទៅកាន់ www.MyIRMobile.com ឬ wa.MyIR.net និងចុះឈ្មោះដោយឥតគិតថ្លៃ។ ប្រសិនបើអ្នកមានគណនី MyIR រួចហើយ អ្នករួចរាល់ហើយ។

**សូមចងចាំថាការផ្ទៀងផ្ទាត់កំណត់ត្រារបស់អ្នកតាមរយៈMyIR មិនអាចធ្វើឡើងភ្លាមៗហើយការទទួលបានគឺត្រូវបានកម្រិតសម្រាប់ភាសាអង់គ្លេសតែប៉ុណ្ណោះ។*

សម្រាប់ជំនួយភាសា ឬជំនួយផ្សេងៗទៀតក្នុងការទទួលកំណត់ត្រារបស់អ្នក អ្នកអាចទូរសព្ទទៅ Office of Immunization and Child Profile (ការិយាល័យនៃការចាក់ថ្នាំបង្ការនិងប្រវត្តិកុមារ)រដ្ឋវ៉ាស៊ីនតោន ក្នុងម៉ោងធ្វើការតាមរយៈលេខ 360-236-3595 ឬទាក់ទងតាមអ៊ីមែលតាមរយៈ waiisrecords@doh.wa.gov។

Washington State Department of Health

DOH 348-809 May 2021 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនដែលស្តាប់មិនឮ ឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬអ៊ីមែល civil.rights@doh.wa.gov។